**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ........................................................


រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ឈ្មោះ ៖ ជា ដារ៉ា
លេខទូរស័ព្ទ ៖ ០២៣ ៧២២៥៦៣ (១១៣៤)
អ៊ីមែល ៖ psd@nbc.org.kh


# ការដាក់ឱ្យដំណើរការជាផ្លូវការសេវាទូទាត់រហ័ស

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦ - ធនាគារជាតិនៃកម្ពុជា ក្រោមកិច្ចសហការជាមួយគ្រឹះស្ថានធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ចំនួន១៣ បានដាក់ឱ្យដំណើរការជាផ្លូវការ "**សេវាទូទាត់រហ័ស**" ដែលជាសេវាថ្មីមួយអាចឱ្យអតិថិជន ទទួលបានមូលនិធិភ្លាមៗដែលឆ្លើយតបទៅនឹងតម្រូវការសាច់ប្រាក់បានទាន់ពេលវេលា ។

គោលបំណងនៃការដាក់ឱ្យដំណើរការ "**សេវាទូទាត់រហ័ស**" គឺដើម្បីផ្តល់មធ្យោបាយបន្ថែម ទៀតសម្រាប់គ្រឹះស្ថានធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើទាំងអស់អនុវត្ត ប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់សងប្រាក់ជាប្រាក់រៀល ឆ្លងគ្រឹះស្ថានសម្រាប់អតិថិជនរបស់ខ្លួននៅគ្រប់ ខេត្ត-ក្រុង ទូទាំងប្រទេសកម្ពុជា ប្រកបដោយភាពរហ័ស សុវត្ថិភាព មានប្រសិទ្ធភាពខ្ពស់ និងអាចជឿ ទុកចិត្តបាន ។ ម្យ៉ាងវិញទៀត សេវានេះនឹងរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់ការប្រើប្រាស់ ប្រាក់រៀលឱ្យបានទូលំទូលាយ បង្កើនតម្លាភាពតាមរយៈការទូទាត់ជាអេឡិចត្រូនិក កាត់បន្ថយចរាចរ សាច់ប្រាក់នៅលើទីផ្សារ បង្កើននូវប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងជាពិសេសលើក កម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ និងចូលរួមអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈការធ្វើទំនើបកម្មប្រព័ន្ធទូទាត់នៅប្រទេស កម្ពុជាឱ្យកាន់តែប្រសើរ ។

បច្ចុប្បន្ន អតិថិជនអាចប្រើប្រាស់សេវានេះនៅទូទាំងប្រទេសកម្ពុជាតាមគ្រឹះស្ថានធនាគារ អេស៊ីលីដា កម្ពុជាសាធារណៈ កាណាឌីយ៉ា វឌ្ឍនៈអាស៊ីចំកាត់ (អេ ប៊ី អេ) វិនិយោគនិងអភិវឌ្ឍន៍កម្ពុជា ហ្វីលីព ស្ថាបនា និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អង្គរមីក្រូហិរញ្ញវត្ថុកម្ពុជា (អេ អឹម ខេ)

វីសិនហ្វាន់ ប្រាសាក់ អម្រីត គ្រេឌីត និងហត្ថាកសិករ ។ សេវានេះនឹងអាចឱ្យអតិថិជនប្រើប្រាស់បានកាន់តែទូលំទូលាយនាពេលឆាប់ៗខាងមុខនៅតាមគ្រឹះស្ថានធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើផ្សេងៗទៀតដែលបាននិងកំពុងដាក់ពាក្យចូលជាសមាជិកជាបន្តបន្ទាប់ ។

## អំពីធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាគឺជាធនាគារកណ្តាលរបស់ព្រះរាជាណាចក្រកម្ពុជា ។ ក្នុងនាមជាអាជ្ញាធររូបិយវត្ថុនិងត្រួតពិនិត្យប្រព័ន្ធធនាគារនៅកម្ពុជា បេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជាគឺកំណត់និងដឹកនាំគោលនយោបាយរូបិយវត្ថុ ក្នុងគោលដៅរក្សានូវស្ថិរភាពថ្លៃ សំដៅរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលមើលគេហទំព័រ ៖ www.nbc.org.kh

## សូមភ្ជាប់ទំនាក់ទំនងជាមួយធនាគារជាតិនៃកម្ពុជា

www.facebook.com/nationalbankofcambodiaofficial
www.twitter.com/nbccambodia
www.youtube.com/nationalbankofcambodia